ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង

# នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

**លេខ:...០៣៧...របក/សផក**

ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

**ខែកុម្ភៈ ឆ្នាំ២០២៥**

## ព័ត៌មានស្តីពីឯកសារ

- ឯកសារសង្ខេប:

| | |
|---|---|
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ចំណងជើង | របាយការណ៍សវនកម្ម |
| ប្រធានប្រតិភូ | លោក **យូន សុជាតិ** |
| អ្នកត្រួតពិនិត្យ | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| សវនដ្ឋាន | **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** |
| ទីកន្លែងឯកសាររឹង | នាយកដ្ឋានសវនកម្មផ្ទៃក្នុង ការិយាល័យសវនកម្មទី២ |
| ទីកន្លែងឯកសារទន់ | ការិយាល័យសវនកម្មទី២ |

- ការបែងចែកឯកសារ:

| ឈ្មោះ | មុខតំណែង/តួនាទី | កន្លែងទទួល |
|---|---|---|
| ឯកឧត្តម **សាយ សំអាល់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ខុទ្ទកាល័យក្រសួង( ដ. ន. ស) |
| លោកជំទាវ **សោម គីមសួគ៌** | អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ | អាជ្ញាធរសវនកម្មជាតិ |
| លោក **ព្រាប សុផាត** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត |

# មាតិកា

**ទំព័រ**

**ផ្នែក កៈ ខ្លឹមសារសង្ខេប................................................................................................ ៣**
១. សាវតារ .................................................................................................... ៣
២. ហានិភ័យគន្លឹះ ............................................................................................ ៣
៣. វិសាលភាពសវនកម្ម ..................................................................................... ៣
៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ ........................................................... ៤
៥. អភិក្រមសវនកម្ម ......................................................................................... ៤
៦. សង្ខេបលទ្ធផលគន្លឹះ ..................................................................................... ៤
៧. សេចក្តីសន្និដ្ឋាន ........................................................................................... ៥
៨. វិធានការកែលម្អ .......................................................................................... ៦
៩. អំណរគុណ ................................................................................................. ៦
**ផ្នែក ខៈ លទ្ធផលសវនកម្មលម្អិត........................................................................................ ៦**
១. ធនធានសវនកម្ម និងខណៈគោលសំខាន់ៗ ...................................................... ៦
២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង ............................................................................. ៧
៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង .......................................................................... ៧
៤. ព័ត៌មានអំពីសវនដ្ឋាន ................................................................................... ៧
៥. លទ្ធផលសវនកម្ម ......................................................................................... ៨
៥.១. ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ ........................................................................ ៨
ក. រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ ............................................................. ៨
ខ. ការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) ..................................................... ៨
គ. ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ......................... ៩
ឃ. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ....................................................................... ១១
ង. ការអនុវត្តការងារសំណង់ .......................................................................... ១១
៦. សេចក្តីសន្និដ្ឋានរួម ........................................................................................ ១៣
៧. ផែនការសកម្មភាពកែលម្អ.............................................................................. ១៣

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី ២ ផែនការសកម្មភាពកែលម្អ
ឧបសម្ព័ន្ធទី ៣ តារាងចំណាយថវិការដ្ឋ និងតារាងប្រើប្រាស់ប្រេងឥន្ធនៈ

# ផ្នែក ក: ខ្លឹមសារសង្ខេប

## ១. សាវតារ

ការធ្វើសវនកម្ម នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សម្រាប់ការិយបរិច្ឆេទ២០២៤ ជាផ្នែកមួយនៃផែនការប្រចាំឆ្នាំ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង លេខ១៤១ ដនស/សផក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ដែលទទួលបានការយល់ព្រមពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបានចុះអនុវត្តតាមលិខិតបញ្ជាបេសកកម្ម លេខ៥១ អរប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥ និងលេខ៥២ អរប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥។ របាយការណ៍នេះមានព័ត៌មានលម្អិតអំពីលទ្ធផលការងារសវនកម្ម និងការផ្តល់អនុសាសន៍ក៏ដូចជាវិធានការរបស់ថ្នាក់គ្រប់គ្រងដែលបានឯកភាពគ្នា។

## ២. **ហានិភ័យគន្លឹះ** ជាទូទៅហានិភ័យអាចរាប់បញ្ចូលនូវៈ

**ហានិភ័យប្រតិបត្តិការៈ** ជាហានិភ័យលើការបាត់បង់ដែលជាលទ្ធផលបរាជ័យនៃដំណើរការមនុស្ស និងប្រព័ន្ធ ឬពីហេតុការណ៍ពីខាងក្រៅ។

**ហានិភ័យហិរញ្ញវត្ថុៈ** ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុត្រូវបានរៀបចំឡើងមិនត្រឹមត្រូវ ធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប។

**ហានិភ័យអនុលោមភាពៈ** ជាលទ្ធភាពដែលសកម្មភាពមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។

ដោយឡែក ការងារសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពត មន្ត្រីសវនករកំណត់បាននូវហានិភ័យមួយចំនួន ក្នុងនោះហានិភ័យគន្លឹះមានៈ

- ការប៉ះពាល់ដល់រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ
- ការប៉ះពាល់ដល់ការងារប្រព័ន្ធព័ត៌មានភូមិសាស្រ្ត(GIS)
- ការប៉ះពាល់ដល់ការងារសុរិយោដី និងភូមិសាស្រ្ត និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- ការប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ការប៉ះពាល់ដល់ការអនុវត្តការងារសំណង់

## ៣. វិសាលភាពសវនកម្ម

សវនកម្មនេះគ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងប្រតិបត្តិការទាំងឡាយដែលបានដំណើរការដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សម្រាប់ការិយបរិច្ឆេទ២០២៤។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើតេស្តសវនកម្មត្រូវបានប្រព្រឹត្តទៅនៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត។

## ៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ

គោលបំណងសវនកម្មរួមគឺវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ចក្នុងទីសវនកម្មដែលស្ថិតនៅក្នុងវិសាលភាពសវនកម្ម។

ជាទូទៅ ការងារសវនកម្មបានផ្តោតសំខាន់ទៅលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលអាចផ្តល់នូវការធានាសមហេតុផលមួយ សំដៅសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- **គោលបំណងប្រតិបត្តិការ៖** ការសម្រេចបានប្រកបដោយប្រសិទ្ធភាព នៃគោលបំណងធុរកិច្ច។
- **គោលបំណងព័ត៌មាន៖** ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ។
- **គោលបំណងអនុលោមភាព៖** អនុលោមជាមួយច្បាប់ បទប្បញ្ញត្តិ គោលការណ៍ នីតិវិធីជាធរមាន។

ដោយឡែក នៅក្នុងសវនកម្មនេះ មន្ត្រីសវនករបានកំណត់នូវគោលបំណងសំខាន់ៗមួយចំនួនដើម្បីគ្រប់គ្រងហានិភ័យដូចជា៖

- ប្រសិទ្ធភាពនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ
- ប្រសិទ្ធភាពនៃការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)
- ប្រសិទ្ធភាពនៃការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ប្រសិទ្ធភាពនៃការអនុវត្តការងារសំណង់

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតលើដំណើរការមានហានិភ័យ ត្រូវបានប្រើប្រាស់នៅក្នុងការងារសវនកម្មនេះ។ អភិក្រមសវនកម្មនេះរាប់បញ្ចូល៖

- កំណត់ត្រានូវប្រព័ន្ធគ្រប់គ្រង (កុងត្រូល) ផ្ទៃក្នុងតាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធ និងសម្ភាសន៍មន្ត្រី
- ការកំណត់នូវកុងត្រូលគន្លឹះ និងធ្វើការប្រៀបធៀបជាមួយកុងត្រូលដែលបានរំពឹងទុក
- តេស្តសវនកម្មនូវប្រសិទ្ធភាពប្រតិបត្តិការនៃកុងត្រូល

តាមរយៈការងារសវនកម្ម ប្រតិភូសវនកម្មបានសហការកំណត់ការរំពឹងទុករួមជាមួយថ្នាក់គ្រប់គ្រង និងសវនដ្ឋានតាមដែលអាចធ្វើទៅបាន។

## ៦. សង្ខេបលទ្ធផលគន្លឹះ

ប្រតិភូសវនកម្មបានកត់សម្គាល់ឃើញនូវចំណុចខ្វះចន្លោះដូចខាងក្រោម៖

*១-រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ*

- **មន្ទីរមានថ្នាក់ដឹកនាំដែលជាអនុប្រធានមន្ទីរចំនួនតែ ០២រូប ប៉ុណ្ណោះ មិនទាន់ឆ្លើយតបទៅនឹងទំហំការងារបច្ចុប្បន្នរបស់មន្ទីរនៅឡើយ។**

*២.ការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)*

-បន្ទប់ដាក់ម៉ាស៊ីនមេ (Server) បន្ទប់ការិយាល័យGIS និងឃ្លាំងទុកដាក់រក្សាឯកសារ ពុំមានបំពាក់ប្រព័ន្ធការពារអគ្គីភ័យ។

*៣-ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី*

-តាមបណ្ដាស្រុកដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច ក្រុមការងារចុះបញ្ជីដីធ្លីមិនបានបញ្ជូនសំណុំឯកសារពាក់ព័ន្ធមកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក។

-ក្រុមការងារចុះបញ្ជីដីធ្លី មិនបាន Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ។

-មន្ទីរមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលខូចចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ចំនួន ១៩,៣១៤ សន្លឹក។

-តាមការពិនិត្យ និងសាកសួរមន្ត្រីជំនាញឃើញថា បណ្ដាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក យឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពចុះសម្រង់បញ្ជីបន្ត ក្នុងសៀវភៅគោលបញ្ជីដីធ្លី។

*៤-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*

-តាមការពិនិត្យតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣ ឃើញថា មន្ទីរមានទោចក្រយានយន្តចំនួន ០៥ គ្រឿងដែលបានបាត់បង់ ប៉ុន្តែមិនទាន់បានស្នើសុំទៅគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីវាយតម្លៃ រួចហើយធ្វើការជម្រះបញ្ជីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរនៅឡើយ។

*៥-ការអនុវត្តការងារសំណង់*

១.តាមការពិនិត្យរបាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ ឃើញថា÷

-ពុំមានទិន្នន័យ លិខិតបើកការដ្ឋាន និងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

-ពុំមានទិន្នន័យ លិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់។

២.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក មិនបានបញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។

## ៧. សេចក្តីសន្និដ្ឋាន

ក្នុងកំឡុងពេលធ្វើសវនកម្ម ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយចំនួនត្រូវបានកត់សម្គាល់ឃើញថា មានការរៀបចំបានល្អ និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ ប្រតិភូសវនកម្មផ្ទៃក្នុងពិនិត្យឃើញថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពតបានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទីភារកិច្ចដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។ ទោះ

ជាយ៉ាងណាក៏ដោយ ក៏នៅទីសវនកម្មមួយចំនួនត្រូវបានសម្គាល់ថា ការតាក់តែងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវការការកែលម្អបន្ថែម និងប្រសិទ្ធភាពប្រតិបត្តិការ នៃការត្រួតពិនិត្យខ្លះនៅមិនទាន់បានល្អគ្រប់ជ្រុងជ្រោយនៅឡើយ។

### ៨. វិធានការកែលម្អ

អនុសាសន៍ដែលបានផ្តល់ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តដំណើរការធុរកិច្ច និងការគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន ត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលលម្អិត(ផ្នែក ខ)។ អនុសាសន៍ និងរបកគំហើញមួយចំនួនត្រូវបានឯកភាពជាមួយថ្នាក់ដឹកនាំជាលាយល័ក្ខអក្សរ។ លទ្ធផលលម្អិត(ផ្នែក ខ) ក៏មានរំលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

វិធានការកែលម្អរបស់ថ្នាក់ដឹកនាំគឺមានរំលេចក្នុងផែនការសកម្មភាពជាឧបសម្ព័ន្ធទី២ ដែលបានភ្ជាប់ជាមួយ។ ផែនការសកម្មភាពកែលម្អមានបញ្ចូលលម្អិតនូវសកម្មភាពដែលសវនដ្ឋានបានឯកភាពទទួលយកដើម្បីអនុវត្តតាមអនុសាសន៍ទាំងនោះ។ អនុសាសន៍នីមួយៗ ត្រូវបានរៀបចំតាមចំណាត់ថ្នាក់ដើម្បីបង្ហាញនូវកម្រិតហានិភ័យដល់ថ្នាក់ដឹកនាំប្រសិនបើអនុសាសន៍នោះមិនត្រូវបានយកទៅអនុវត្ត។

នាពេលអនាគត នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងពិនិត្យឡើងវិញលើវឌ្ឍនភាព នៃការអនុវត្តតាមអនុសាសន៍ដែលបានផ្តល់ជូនដែលជាផ្នែកមួយនៃនីតិវិធីតាមដានអនុសាសន៍សវនកម្មគ្រាមុន។

### ៩. អំណរគុណ

ក្រុមការងារសវនកម្មត្រូវបានដឹកនាំ និងត្រួតពិនិត្យដោយលោក **ឃួន សុជាតិ** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងជាប្រធានប្រតិភូ។ ប្រតិភូសវនកម្មផ្ទៃក្នុងសូមថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធដែលបានរួមចំណែកក្នុងការងារសវនកម្មនេះ ជាពិសេសសូមថ្លែងអំណរគុណដល់លោក **ព្រាប សុផាត** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត និងថ្នាក់ដឹកនាំដទៃទៀតចំពោះកិច្ចសហការពិគ្រោះ និងផ្តល់ព័ត៌មានព្រមទាំងមតិយោបល់ដ៏មានតម្លៃ។

## ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

### ១. ធនធានសវនកម្ម និងគោលសំខាន់ៗ

#### ១.១. សមាជិកប្រតិភូសវនកម្ម

នៅក្នុងការងារសវនកម្មនេះ ប្រតិភូសវនកម្មមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-លោក | **ឃួន សុជាតិ** | ប្រធានប្រតិភូ |
| ២-លោក | **ងួន សុវឌ្ឍនា** | អនុប្រធានប្រតិភូ |
| ៣-លោក | **រតន៍ អរិយ៍** | សមាជិក |
| ៤-លោក | **ជា សីង្ហវុធ** | សមាជិក |
| ៥-លោកស្រី | **វៀម នារីរ័ត្ន** | សមាជិក |
| ៦-លោក | **អេ ប៊ុនថេត** | សមាជិក |

### ១.២ ខណៈគោលសំខាន់ៗ

ខាងក្រោមគឺជាខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្មៈ

| | |
|---|---|
| -ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥ |
| -សេចក្តីព្រាងលើកទី១ បានបញ្ចប់ | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥ |
| -ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល | ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ |
| -របាយការណ៍ស្ថាពរ | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៥ |

## ២.និដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុងគឺជួយថ្នាក់ដឹកនាំធ្វើឱ្យកាន់តែល្អប្រសើរឡើងក្នុងដំណើរការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំ និងមន្ត្រីដទៃទៀតដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោមៈ

- របាយការណ៍ហិរញ្ញវត្ថុគួរឱ្យទុកចិត្តបាន
- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និង
- ការអនុវត្តតាមច្បាប់ និងបទដ្ឋាននានា។

របាយការណ៍នេះរួមមានការពិនិត្យលើការតាក់តែង និងប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដោយសវនករនៅទីសវនកម្មអាទិភាពមួយចំនួនដែលបានឯកភាពជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន។

## ៣ .ការពិនិត្យប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយធ្វើការពិនិត្យលើសមត្ថភាពនៃដំណើរការគ្រប់គ្រងនីមួយៗ ដើម្បីសម្រេចឱ្យបានគោលបំណងគ្រប់គ្រងចំនួនប្រាំពីរមានៈ ការផ្តល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព សុវត្ថិភាពរូបវន្ត ការដោះស្រាយកំហុស និងការបែងចែកតួនាទី។

## ៤.ព័ត៌មានអំពីសវនដ្ឋាន

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពតមានភារកិច្ចអនុវត្តគោលនយោបាយ និងទិសដៅការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពតមាន÷

- ការិយាល័យរដ្ឋបាល ការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម ការិយាល័យសំណង់ ការិយាល័យលំនៅឋាន និងការិយាល័យសុរិយោដី និងភូមិសាស្ត្រ។
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងកំពត ក្រុងបូកគោ ស្រុកអង្គរជ័យ ស្រុកដងទង់ ស្រុកឈូក ស្រុកទឹកឈូ ស្រុកបន្ទាយមាស ស្រុកកំពង់ត្រាច ស្រុកជុំគិរី(ប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង តាមអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ

ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង និងស្រុក តាមអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក)។

- មន្ត្រីសរុបចំនួន **៤៧** រូប ស្រី **០៩** រូប ដឹកនាំដោយប្រធានមន្ទីរមួយរូប និងអនុប្រធានមន្ទីរចំនួនពីររូប។

## ៥. លទ្ធផលសវនកម្ម

### ៥.១.ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

#### ក.រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ជាក់ស្តែងក្រោយសវនកម្ម មន្ត្រីសវនករបានពិនិត្យឃើញថា÷

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យរចនាសម្ព័ន្ធរបស់មន្ទីរមានភាពពេញលេញដើម្បីដំណើរការការងារប្រកបដោយប្រសិទ្ធភាព។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

មន្ទីរមានថ្នាក់ដឹកនាំដែលជាអនុប្រធានមន្ទីរចំនួនតែ ០២រូប ប៉ុណ្ណោះ មិនទាន់ឆ្លើយតបទៅនឹងទំហំការងារបច្ចុប្បន្នរបស់មន្ទីរនៅឡើយ។

**ករណីខាងលើ** មិនអនុលោមតាមប្រកាសលេខ៧៦ ប្រក/ដនស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ។

**បាតុភាពនេះ** កើតឡើងដោយសារមន្ទីរមិនទាន់បានរៀបចំចាត់ចែងក្នុងការស្នើសុំតែងតាំងអនុប្រធានមន្ទីរបន្ថែមមួយរូបទៀត។

**កត្តានេះ** នាំឱ្យរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរមិនទាន់បានពេញលេញ។

**មន្ទីរ** គួរពិចារណាស្នើសុំតែងតាំងអនុប្រធានមន្ទីរ ០១ រូប បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងទំហំការងារមមាញឹកជាក់ស្តែង។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** នឹងរៀបចំស្នើសុំតែងតាំងអនុប្រធានមន្ទីរ ០១ រូប បន្ថែមទៀត ក្នុងពេលឆាប់ៗខាងមុខនេះ។

**ប្រតិភូសវនករ** នឹងបន្តតាមដាននាពេលខាងមុខទៀត។

#### ខ.ការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានសុវត្ថិភាព ចំពោះការរក្សាឯកសារសុរិយោដី និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

-បន្ទប់ដាក់ម៉ាស៊ីនមេ (Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារ ពុំទាន់មានបំពាក់ប្រព័ន្ធការពារអគ្គិភ័យ។

**ករណីខាងលើ** មិនអនុលោមតាមប្រកាសលេខ១៤៣៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារស្តីពីការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន និងប្រកាសលេខ៧៦ ប្រក/ដនស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ។

**បាតុភាពនេះ** កើតឡើងដោយសារការគ្រប់គ្រងបន្ទប់ម៉ាស៊ីនមេ (Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារនៅខ្វះចន្លោះ។

**កត្តានេះ** ប៉ះពាល់ដល់សុវត្ថិភាព នៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងឯកសារសុរិយោដី។

**មន្ទីរ** ត្រូវបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារជាបន្ទាន់។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** នឹងបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារ ក្នុងពេលឆាប់ៗនេះ។

**ប្រតិភូសវនករ** នឹងបន្តតាមដាននាពេលខាងមុខទៀត។

**គ.ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី**

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ក្នុងការអនុវត្តការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

-តាមបណ្តាស្រុកដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច ក្រុមការងារចុះបញ្ជីដីធ្លី មិនបានបញ្ជូនសំណុំឯកសារពាក់ព័ន្ធមកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក។

-ក្រុមការងារចុះបញ្ជីដីធ្លី មិនបាន Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ។

-មន្ទីរមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលខូចចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ចំនួន **១៩,៣១៤** សន្លឹក។

-តាមការពិនិត្យ និងសាកសួរមន្ត្រីជំនាញឃើញថា បណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក យឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពចុះសម្រង់បញ្ជីបន្ត ក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**ករណីខាងលើនេះ** មិនអនុលោមទៅតាមសារាចរណែនាំលេខ០០៣ ដនស.សជ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ)។

**បាតុភាពនេះ** កើតឡើងដោយសារៈ

-ចន្លោះប្រហោងក្នុងការអនុវត្តការងាររបស់ក្រុមការងារចុះបញ្ជីដីធ្លី

-បញ្ហាទឹកថ្នាំ និងត្រាម

-បញ្ហា QR Code មិនដំណើរការ

-មន្ត្រីទទួលបន្ទុកក្នុងការព្រីនសន្លឹកបណ្ណមានការធ្វេសប្រហែស (ព្រីនម្តងខុសលេខក្បាលដីខាងមុខ ព្រីនម្តងខុសលេខក្បាលដីខាងក្រោយ)។

-ភាពយឺតយ៉ាវរបស់បណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុកក្នុងការចុះសម្រង់បញ្ជីបន្ត។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

**មន្ទីរ** ត្រូវ÷

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីបណ្តាក្រុង-ស្រុក ដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច បញ្ជូននូវរាល់សំណុំឯកសារពាក់ព័ន្ធ មកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ឱ្យបានទៀងទាត់។

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីធ្វើការ Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរឱ្យបានពេញលេញ។

-ធ្វើបច្ចុប្បន្នភាពសន្លឹកបណ្ណខូច រួចហើយស្នើសុំបង្កើត គណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងប្លូកសរុប ដើម្បីដុតកម្ទេច ស្របតាមលិខិតលេខ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

-ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ធ្វើការចុះបញ្ជីបន្តនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឱ្យបានពេញលេញ។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** នឹង÷

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីតាមបណ្តាក្រុង-ស្រុក ដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច បញ្ជូននូវរាល់សំណុំឯកសារពាក់ព័ន្ធ មកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុកបានទៀងទាត់។

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីធ្វើការ Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ។

-ធ្វើលិខិតស្នើសុំទៅក្រសួង ដើម្បីចាត់តាំងក្រុមការងារបច្ចេកទេស នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ចូលរួមបង្កើតជាគណៈកម្មការកម្ទេចសន្លឹកបណ្ណដែលខូច រួចហើយធ្វើការដុតកម្ទេចចោល។

-ធ្វើការជំរុញ និងណែនាំឱ្យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ធ្វើការចុះបញ្ជីបន្ត នៅក្នុងសៀវភៅគោលបញ្ជីដីធ្លីឱ្យបានទាន់ពេលវេលា។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

**ឃ.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ជាក់ស្តែងក្រោយសវនកម្ម មន្ត្រីសវនករបានពិនិត្យឃើញថា÷

តាមការពិនិត្យតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣ ឃើញថា មន្ទីរមានទោចក្រយានយន្តចំនួន ០៥ គ្រឿង ដែលបានបាត់បង់ ប៉ុន្តែមិនទាន់បានស្នើសុំទៅគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីវាយតម្លៃ រួចហើយធ្វើការជម្រះបញ្ជីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរនៅឡើយ។

**ករណីនេះ** អនុវត្តពុំទាន់សមស្របតាមសារាចរណែនាំលេខ០០១ សហវ.ទរ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលការធ្វើបញ្ជីសារពើរភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**បាតុភាពនេះ** កើតឡើងដោយសារនៅក្នុងតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣ ឃើញមានទោចក្រយានយន្តចំនួន ០៥ គ្រឿងបានបាត់បង់។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មន្ទីរ** ត្រូវរួសរាន់ក្នុងការកែតម្រូវសៀវភៅកើនឡើងឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំ២០២៤ ដើម្បីជៀសវាងមានការចុះច្រឡំបន្តថា មានការបាត់បង់ទោចក្រយានយន្តចំនួន ០៥គ្រឿង នៅក្នុងសៀវភៅកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរ ប្រចាំឆ្នាំ២០២៤។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** បានបញ្ជាក់ថា ទោចក្រយានយន្តនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរមានចំនួន ២១គ្រឿង។ នៅពេលពិនិត្យ និងរាប់ជាក់ស្តែងឃើញមានចំនួន១៧ គ្រឿងនៅនឹងមន្ទីរ និងចំនួន០៤ គ្រឿងទៀត មន្ទីរបានប្រគល់ជូនលោក **ម៉ែន មុន្នី លោក សំ ស៊ីណាត លោក ឥន្ទ ឈឿន** និង**លោកស្រី អ៊ុក ចាន់ថន** ធ្វើការជួសជុល ហើយប្រើប្រាស់មួយរយៈពេលសិន។ ចំពោះទោចក្រយានយន្តដែលចុះច្រឡំថាបានបាត់បង់ចំនួន ០៥ គ្រឿងនៅក្នុងសៀវភៅកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋ សម្រាប់ឆ្នាំ២០២៣ មន្ទីរស្នើសុំធ្វើការកែតម្រូវឡើងវិញ។

**ប្រតិភូសវនករ** នឹងបន្តតាមដាននាពេលខាងមុខទៀត។

**ង.ការអនុវត្តការងារសំណង់**

គោលបំណងនៃការត្រួតពិនិត្យនេះគឺធ្វើឱ្យមានភាពត្រឹមត្រូវ ច្បាស់លាស់ក្នុងការអនុវត្តការងារសំណង់។ ក្រោយធ្វើសវនកម្ម មន្ត្រីសវនករពិនិត្យឃើញថា÷

១.តាមការពិនិត្យរបាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ ឃើញថា÷

-ពុំមានទិន្នន័យ លិខិតបើកការដ្ឋាន និងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

-ពុំមានទិន្នន័យ លិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់។

២.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក មិនបានបញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។

**ករណីខាងលើ** មិនអនុលោមតាមប្រកាសលេខ៧៦ ប្រក/ដនស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ។

**បាតុភាពនេះ** កើតឡើងដោយសារការអនុវត្តការងារសំណង់មិនបានគ្រប់ជ្រុងជ្រោយ។

**កត្តានេះ** នាំឱ្យប៉ះពាល់ដល់ការអនុវត្តការងារសំណង់របស់មន្ទីរ។

**មន្ទីរ** ត្រូវ÷

-រំលេចទិន្នន័យ លិខិតបើកការដ្ឋានវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំរបស់មន្ទីរ ព្រមទាំងខិតខំជំរុញការផ្សព្វផ្សាយណែនាំឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន មុននឹងធ្វើការសាងសង់ និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្រោយបញ្ចប់ការសាងសង់។ មន្ទីរក៏ត្រូវណែនាំក្រុមជាងសំណង់ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់មុនពេលដំណើរការអាជីវកម្ម ស្របតាមសារាចរណែនាំស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ លេខ០០១ ដនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

-ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត** នឹង÷

-ខិតខំប្រឹងប្រែងជំរុញការផ្សព្វផ្សាយ និងណែនាំបន្ថែមទៀត ដើម្បីឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់ និងស្នើសុំលិខិតអនុញ្ញាតបិទការដ្ឋានក្រោយបញ្ចប់ការសាងសង់ (វិញ្ញាបនបត្រប្រើប្រាស់សំណង់)។

-ធ្វើការរំលេចទិន្នន័យ លិខិតបើកការដ្ឋាន វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំរបស់មន្ទីរ ព្រមទាំងខិតខំប្រឹងប្រែងជំរុញការផ្សព្វផ្សាយ និងការណែនាំបន្ថែមទៀត ដើម្បីឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់ និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្រោយបញ្ចប់ការសាងសង់។ មន្ទីរក៏នឹងខិតខំណែនាំក្រុមជាងសំណង់ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់មុនពេល

ដំណើរការអាជីវកម្ម ស្របតាមសារាចរណែនាំស្តីពីការគ្រប់គ្រងក្រុមជាងសំណង់លេខ០០១ ដនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

-ជំរុញ និងណែនាំទៅបណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ មកការិយាល័យសំណង់របស់មន្ទីរ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់។

**ប្រតិភូសវនករ** បានទទួលការឆ្លើយតបពីថ្នាក់ដឹកនាំមន្ទីរ និងបន្តតាមដាននាពេលខាងមុខទៀត។

## ៦. សេចក្តីសន្និដ្ឋានរួម

ផ្អែកតាមលទ្ធផលធ្វើសវនកម្មជាក់ស្តែងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សម្រាប់ការិយបរិច្ឆេទ២០២៤ លើប្រព័ន្ធគ្រប់គ្រង និងយន្តការនៃដំណើរការក្នុងវិសាលភាព និងគោលបំណងខាងលើ ប្រតិភូសវនកម្មផ្ទៃក្នុងអាចធ្វើសេចក្តីសន្និដ្ឋានលើចំណុចខ្វះចន្លោះ ដែលត្រូវពង្រឹងបន្ថែមមានដូចជា រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ ការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការអនុវត្តការងារសំណង់ ដើម្បីជំរុញប្រសិទ្ធភាពការងារឱ្យបានប្រសើរឡើងនាឆ្នាំបន្ទាប់។

## ៧ .ផែនការសកម្មភាពកែលម្អ

ដើម្បីធានាប្រសិទ្ធភាពអនុវត្តការកែលម្អអនុសាសន៍ដែលប្រតិភូសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពតបានឯកភាពលើផែនការសកម្មភាពដូចបានកំណត់ក្នុងតារាងនៃឧបសម្ព័ន្ធទី២។

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៥

**ប្រធាននាយកដ្ឋាន**

យួន សុជាតិ

## ២. ឧបសម្ព័ន្ធទី ២ -ផែនការសកម្មភាពកែលម្អ

របាយការណ៍ : សវនកម្មនៅ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ការិយបរិច្ឆេទ២០២៤**

របាយការណ៍លេខ: ......០៣៥...... /របក ចុះថ្ងៃទី......២៥...... ខែ......កុម្ភៈ...... ឆ្នាំ២០២៥

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាត ងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់ពង្រឹងប្រព័ន្ធ និងនីតិវិធី
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ឬចងក្រងឯកសារក្នុងទីដែល មិនសូវសំខាន់
- អ.ព: អនុវត្តតាមអនុសាសន៍ឱ្យបានពេញលេញ និងកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន ។

| **អនុសាសន៍លេខ** | **សកម្មភាពដែលថ្នាក់ដឹកនាំបានឯកភាព** | **អាទិភាព*** | **មន្ត្រីទទួលបន្ទុក** | **កាលបរិច្ឆេទឯកភាពបញ្ចប់ការអនុវត្ត** |
|---|---|---|---|---|
| **១. ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ** | | | | |
| **ក.** មន្ទីរគួរពិចារណាស្នើសុំតែងតាំងអនុប្រធានមន្ទីរ ០១ រូប បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងទំហំការងារមមាញឹកជាក់ស្តែង។ | អ.ព | ខ្ពស់ | ប្រធានមន្ទីរ | មន្ទីរនឹងរៀបចំស្នើសុំតែងតាំងអនុប្រធានមន្ទីរ ០១ រូប បន្ថែមទៀត ក្នុងពេលឆាប់ៗខាងមុខនេះ។ |
| **ខ.** មន្ទីរត្រូវបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (Server) បន្ទប់ការិយាល័យGIS និងឃ្លាំងទុកដាក់រក្សាឯកសារជាបន្ទាន់។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរនឹងបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server) បន្ទប់ការិយាល័យGIS និងឃ្លាំងទុកដាក់រក្សាឯកសារ ក្នុងពេលឆាប់ៗនេះ។ |
| **គ.** មន្ទីរត្រូវ÷<br>-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីបណ្តាក្រុង-ស្រុកដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច បញ្ជូននូវរាល់សំណុំ | អ.ព | ខ្ពស់ | ប្រធានមន្ទីរ | មន្ទីរនឹង÷<br>-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីតាមបណ្តាក្រុង-ស្រុក ដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច បញ្ជូន |

| | | | | |
|---|---|---|---|---|
| ឯកសារពាក់ព័ន្ធ មកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ឱ្យបានទៀងទាត់។<br>-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីធ្វើការ Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ ឱ្យបានពេញលេញ។<br>-ធ្វើបច្ចុប្បន្នភាពសន្លឹកបណ្ណខូចរួចហើយស្នើសុំបង្កើត គណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុប ដើម្បីដុតកម្ទេច ស្របតាមលិខិតលេខ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។<br>-ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ធ្វើការចុះបញ្ជីបន្ត នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឱ្យបានពេញលេញ។ | | | | នូវរាល់សំណុំឯកសារពាក់ព័ន្ធ មកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុកបានទៀងទាត់។<br>-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីធ្វើការ Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ ជាប្រចាំ។<br>-ធ្វើលិខិតស្នើសុំទៅក្រសួង ដើម្បីចាត់តាំងក្រុមការងារបច្ចេកទេស នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ចូលរួមបង្កើតជាគណៈកម្មការកម្ទេចសន្លឹកបណ្ណដែលខូចរួចហើយធ្វើការដុតកម្ទេចចោល។<br>-ធ្វើការជំរុញ និងណែនាំឱ្យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ធ្វើការចុះបញ្ជីបន្តនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីឱ្យបានទាន់ពេលវេលា។ |
| **ឃ.** មន្ទីរត្រូវរួសរាន់ក្នុងការកែតម្រូវសៀវភៅកើនឡើងឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំ២០២៤ ដើម្បីជៀសវាងមានការចុះច្រឡំបន្តថា មានការបាត់បង់ទោចក្រយានយន្តចំនួន ០៥គ្រឿង នៅក្នុង | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរបានបញ្ជាក់ថា ទោចក្រយានយន្តនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរមានចំនួន ២១គ្រឿង។ នៅពេលពិនិត្យ និងរាប់ជាក់ស្តែង ឃើញមានចំនួន១៧ គ្រឿង នៅនឹងមន្ទីរ និងចំនួន០៤ គ្រឿងទៀត មន្ទីរបានប្រគល់ |

| | | | | |
|---|---|---|---|---|
| សៀវភៅកើនឡើងឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរ ប្រចាំឆ្នាំ២០២៤។ | | | | ជូនលោក **ម៉ែន មុន្នី លោក សំ ស៊ីណាត លោក ឥន្ទ ឈឿន** និង**លោកស្រី អ៊ុក ចាន់ថន** ធ្វើការជួសជុល ហើយប្រើប្រាស់មួយរយៈពេលសិន។ ចំពោះទោចក្រយានយន្តដែលចុះច្រឡំថាបានបាត់បង់ចំនួន ០៥ គ្រឿងនៅក្នុងសៀវភៅកើនឡើងឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋ សម្រាប់ឆ្នាំ២០២៣ មន្ទីរស្នើសុំធ្វើការកែតម្រូវឡើងវិញ។ |
| **ង.** មន្ទីរត្រូវ÷<br>-រំលេចទិន្នន័យ លិខិតបើកការដ្ឋាន វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំរបស់មន្ទីរ ព្រមទាំងខិតខំជំរុញការផ្សព្វផ្សាយណែនាំឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន មុននឹងធ្វើការសាងសង់ និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្រោយបញ្ចប់ការសាងសង់។ មន្ទីរក៏ត្រូវណែនាំក្រុមជាងសំណង់ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់មុនពេលដំណើរការអាជីវកម្ម ស្របតាមសារាចរ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរនឹង÷<br>-ធ្វើការរំលេចទិន្នន័យ លិខិតបើកការដ្ឋាន វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំរបស់មន្ទីរ ព្រមទាំងខិតខំប្រឹងប្រែងជំរុញការផ្សព្វផ្សាយ និងការណែនាំបន្ថែមទៀត ដើម្បីឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់ និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្រោយបញ្ចប់ការសាងសង់។ មន្ទីរក៏នឹងខិតខំណែនាំក្រុមជាងសំណង់ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់មុនពេលដំណើរការអាជីវកម្ម ស្របតាមសារាចរណែនាំស្តីពីការ |

| | | | | |
|---|---|---|---|---|
| ណែនាំស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ លេខ០០១ ដនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។<br>-ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់មកការិយាល័យសំណង់របស់មន្ទីរ។ | | | | គ្រប់គ្រងក្រុមជាងសំណង់លេខ០០១ ដនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។<br>-ជំរុញ និងណែនាំទៅបណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ មកការិយាល័យសំណង់របស់មន្ទីរ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់។ |

**ប្រធានមន្ទីរ**

ព្រាប_សុផាត

**ប្រតិភូសវនករ**

យួន_សុជាតិ

៣. ឧបសម្ព័ន្ធទី ៣- តារាងចំណាយថវិការដ្ឋ និងតារាងប្រើប្រាស់ប្រេងឥន្ធនៈ

**៣.១.តារាងចំណាយថវិការដ្ឋ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត**

| ល.រ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៤ | ឥណទានថ្មី | ទឹកប្រាក់តាមអាណត្តិ | បង់សំណែសចំណាយ | ចំណាយជាក់ស្តែង | ផ្សេងៗ | សមតុល្យ |
|---|---|---|---|---|---|---|---|---|
| ១ | ការទិញ (ជំពូក ៦០) | 144.800.000 | 144.800.000 | 122.082.560 | 0 | 122.082.560 | 0 | 22.717.440 |
| ២ | សេវាខាងក្រៅ (ជំពូក ៦១) | 103.700.000 | 103.700.000 | 103.427.811 | 0 | 103.427.811 | 0 | 272.189 |
| ៣ | បន្ទុកបុគ្គលិក( ជំពូក ៦៤ ) | 1.033.900.000 | 1.033.900.000 | 1.020.081.180 | 0 | 1.020.081.180 | 0 | 13.818.820 |
| សរុប | | **1.282.400.000** | **1.282.400.000** | **1.245.591.551** | **0** | **1.245.591.551** | **0** | **36.808.449** |

ថ្ងៃព្រហស្បត្តិ៍១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥

បានឃើញ និងឯកភាព
**ប្រធានមន្ទីរ**
ព្រាប_សុជាត

បានឃើញ និងពិនិត្យត្រឹមត្រូវ
**ប្រធានការិយាល័យរដ្ឋបាល**
ថៃ_ចាន់

**ប្រតិភូសវនករ**
យួន_សុជាតិ

### ៣.២. តារាងប្រើប្រាស់ប្រេងឥន្ធនៈ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

| ល.រ | ប្រភេទប្រេងឥន្ធនៈ | បញ្ចូល | | បញ្ចេញ | សមតុល្យ |
|---|---|---|---|---|---|
| | | ផ្គត់ផ្គង់ | រដ្ឋទេយ្យ | | |
| ១ | ប្រេងសាំង (លីត្រ) | 9.663 | 0 | 9.663 | 0 |
| ២ | ប្រេងម៉ាស៊ូត | 1.134 | 0 | 1.134 | 0 |

ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥

បានឃើញ និងឯកភាព

**ប្រធានមន្ទីរ**

ព្រាប_សុជាត

បានឃើញ និងពិនិត្យត្រឹមត្រូវ

**ប្រធានការិយាល័យរដ្ឋបាល**

ថៃ_ចាន់

**ប្រតិភូសវនករ**

យួន_សុជាតិ